FIAS

# កម្ពុជា

## ការទទួលខុសត្រូវផ្នែកសង្គមរបស់ក្រុមហ៊ុនសាជីវកម្មនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់

## និង

## ផលប៉ះពាល់ដែលអាចកើតមានចំពោះវិស័យឧស្សាហកម្មដទៃ

*ខែ មេសា ឆ្នាំ ២០០៥*

# ១.០ ខ្លឹមសារសង្ខេប

កិច្ចព្រមព្រៀងសរសៃអំបោះ ឬហៅកាត់ថា MFA បានគ្រប់គ្រងពាណិជ្ជកម្មពិភពលោកនៅក្នុងផ្នែកសំលៀកបំពាក់និងវាយនភណ្ឌចាប់តាំងពីឆ្នាំ ១៩៧៤ មកម្ល៉េះ។ ប្រព័ន្ធកូតាបានធ្វើឱ្យចំនួនប្រទេសផលិតសំលៀកបំពាក់សំរាប់នាំចេញកើនឡើងដោយសិប្បនិម្មិត ដោយដាក់កំហិតលើផលិតផលបែបណាប្រទេសដែលមានភាពប្រកួតប្រជែងបំផុត ហើយអាហារិនរកប្រភពនាំចូលពីប្រទេសមួយ ឬពីប្រទេសមួយទៀត ដោយសារតែមានកូតា។ ប្រការនេះធ្វើឱ្យមានការអភិវឌ្ឍន៍ឧស្សាហកម្មសំលៀកបំពាក់នៅក្នុងប្រទេសនានាដែលគ្មានលក្ខណៈប្រកួតប្រជែង គេចចេញផុតពីការប្រកួតប្រជែងដ៏ស្វិតស្វាញនៅលើពិភពលោក។ ផលវិបាកចំពោះឧស្សាហកម្មនេះគឺវត្តមាននៃសមត្ថភាពច្រើនហួសនិង អប្រសិទ្ធភាពនៅលើពិភពលោក។

កិច្ចព្រមព្រៀងក្នុងកិច្ចប្រជុំនៅ Uruguay បានដាក់កំណត់រយៈពេលបញ្ឈប់កិច្ចព្រមព្រៀង MFA ជាបណ្តើរៗក្នុងរយៈពេល ១០ ឆ្នាំ។ រយៈពេលនេះបានឈានចូលដល់ចុងបញ្ចប់នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥ ដែលលុបបំបាត់កូតាវាយនភណ្ឌនិងកូតាសំលៀកបំពាក់ទាំងអស់សំរាប់ប្រទេសជាសមាជិកនៃអង្គការ WTO។ ការសំរេចចិត្តរបស់វិនិយោគិន និងការសំរេចចិត្តរបស់អ្នកទិញ លែងផ្អែកលើមូលដ្ឋាននៃវត្តមានរបស់កូតាទៀតហើយ។ ឥលូវនេះពួកគេអាចរកទិញពីប្រទេស ឬពីរោងចក្រណាមួយដោយឈរលើមូលដ្ឋាននៃភាពប្រកួតប្រជែងរបស់ខ្លួន ផ្អែកលើលទ្ធភាពចូលទៅកាន់ទីផ្សារ ផ្អែកលើការអនុគ្រោះពន្ធគយ និងពាណិជ្ជកម្ម។ អ្នកសង្កេតការណ៍ភាគច្រើនរំពឹងថានឹងមានការច្របាច់បញ្ចូលគ្នា នូវឧស្សាហកម្មកាត់ដេរនៅលើពិភពលោកទៅកាន់បណ្តាប្រទេសដែលមានប្រសិទ្ធភាពបំផុត និងទៅកាន់រោងចក្រដែលមានប្រសិទ្ធភាពបំផុត ទោះបីជាអន្តរកាលទៅកាន់ក្តីរំពឹងនោះអាចមានត្រូវបានពន្យឺតដោយសារការដាក់វិធានការការពារនៅ សហរដ្ឋអាមេរិក និងនៅអឺរ៉ុបសំរាប់ហេតុផលនយោបាយក្នុងស្រុកក្តី។

ឧស្សាហកម្មនាំសំលៀកបំពាក់ចេញរបស់កម្ពុជាបានចាប់ផ្តើមនៅឆ្នាំ ១៩៩៥ ដែលទឹកប្រាក់នាំចេញមានចំនួនត្រឹមតែ ២០ លានដុល្លារអាមេរិកតែប៉ុណ្ណោះ។ នៅឆ្នាំ ២០០៤ ប្រទេសកម្ពុជាបាននាំចេញសំលៀកបំពាក់ដែលមានតំលៃចំនួន ១,៦ ពាន់លានដុល្លារ។ ផលិតកម្មរបស់កម្ពុជាមានបរិមាណតិចជាង ១% នៃឧស្សាហកម្មកាត់ដេរពិភពលោក ប៉ុន្តែវិស័យនេះបានក្លាយទៅជាវិស័យដែលនាំមកនូវរូបិយប័ណ្ណខ្លាំងធំជាង

វិស័យដទៃទៀតនៅកម្ពុជា ដែលមានបរិមាណស្មើនឹង ៨០% នៃបរិមាណនាំចេញសរុប និងស្មើនឹង ១២,៤% នៃ GDP ។

កេរ្តិ៍ឈ្មោះរបស់កម្ពុជាក្នុងឋានៈជាប្រទេសដែល "គ្មានការបង្ខំឱ្យកម្មករធ្វើការនិងមានកន្លែងធ្វើការដែលមានលក្ខណៈអំណោយផល "មានប្រភពមកពី កិច្ចព្រមព្រៀងពាណិជ្ជកម្មតែមួយ (គ្មានពីរ)ជាមួយសហរដ្ឋអាមេរិក។ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានសន្យាពិចារណាក្នុងការបែងចែករង្វាន់កូតាប្រចាំឆ្នាំ ប្រសិនបើកម្ពុជាអាចបង្ហាញឱ្យឃើញនូវការកែលំអស្តង់ដារការងារ។ រាជរដ្ឋាភិបាលកម្ពុជា សមាគមកាត់ដេររបស់កម្ពុជា រដ្ឋាភិបាលសហរដ្ឋអាមេរិក និងអង្គការពលកម្មអន្តរជាតិបានឯកភាពលើគំនិតផ្តួចផ្តើមរៀបចំគំរោងកែលំអស្តង់ដារការងារ តាមដានការកែលំអ និងរាយការណ៍អំពីកិច្ចការទាំងនោះ។ នៅក្នុងរយៈពេលប្រាំឆ្នាំគំរោងនេះបានទទួលជោគជ័យក្នុងការកែលំអនូវការអនុលោមតាមស្តង់ដារការងារ និងក្នុងការទទួលបាននូវរង្វាន់កូតាសំរាប់ផលិតករកាត់ដេរសំលៀកបំពាក់កម្ពុជា។

ជាមួយនឹងការបញ្ចប់កិច្ចព្រមព្រៀង MFA កិច្ចព្រមព្រៀងរវាងសហរដ្ឋអាមេរិកនិងកម្ពុជាក្លាយទៅជាគ្មានសារប្រយោជន៍ ហើយក្រសួងពាណិជ្ជកម្មបានស្នើការឧបត្ថម្ភគាំទ្រពីអង្គការ FIAS ឱ្យជួយរដ្ឋាភិបាលនិងជួយឧស្សាហកម្មនេះក្នុងការរៀបចំប្រព័ន្ធស្តង់ដារការងារសារជាថ្មី ដែលមិនទាក់ទងជាមួយនឹងសេចក្តីសំរេចចិត្តលើកូតារបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកទៅកាន់យុទ្ធសាស្ត្រដែលដឹកនាំដោយទីផ្សារ។

ជំហានទីមួយគឺត្រូវស្វែងយល់នូវការសន្មតិដែលថាមានមូលដ្ឋានទីផ្សារនាំចេញរឹងមាំផ្អែកលើមូលដ្ឋានស្តង់ដារការងារផ្សារភ្ជាប់ជាមួយលក្ខណៈវិនិច្ឆ័យធម្មតាអំពីថ្លៃ គុណភាព និងល្បឿនបញ្ជូនទៅកាន់ទីផ្សារ - តើនឹងមានអ្នកទិញគ្រប់គ្រាន់បន្តទិញពីកម្ពុជាដែរឬទេ ដែលការបន្តទិញនោះពុំមែនបណ្តាលមកពីការបែងចែកកូតា ដែលធ្វើឱ្យទីផ្សារបាត់បង់នូវដំណើរការប្រក្រតីនោះទេ ប៉ុន្តែគឺដោយសារពួកគេក្នុងចាប់អារម្មណ៍លើស្តង់ដារការងារ? អង្កេតមួយដែលបានធ្វើចំពោះអ្នកទិញសំខាន់ៗមកពីសហរដ្ឋអាមេរិកនិងមកពីអឺរ៉ុបដែលបានទិញសំលៀកបំពាក់ពីកម្ពុជាបញ្ជាក់អំពីមូលដ្ឋានទីផ្សាររឹងមាំនេះ។ អ្នកទិញពុំមែនត្រឹមតែចាត់ថ្នាក់លើការអនុវត្តន៍តាមស្តង់ដារការងារធ្វើជាអាទិភាពមួយខ្ពស់តែប៉ុណ្ណោះទេ ប៉ុន្តែអ្នកទិញមួយចំនួនធំបញ្ជាក់ថាការធ្វើអធិការកិច្ចលើស្តង់ដារការនៅតែមានសារៈសំខាន់។

ឧត្តមភាពលើស្តង់ដារការងារនេះគឺជាកត្តាតែមួយគត់ ដែលអ្នកទិញមានជំនឿថាប្រទេសកម្ពុជាអនុវត្តបានល្អជាងគូប្រជែងរបស់ខ្លួននៅក្នុងតំបន់។

ជំហានបន្ទាប់នៅក្នុងគំរោងប្រឹក្សាគឺត្រូវធ្វើការជាមួយភាគីពាក់ព័ន្ធក្នុងការរៀបចំឡើងវិញនូវប្រព័ន្ធតាមដាន និងប្រព័ន្ធរាយការណ៍បច្ចុប្បន្ន តាមបែបមួយដែលការធ្វើសមាហរណកម្មនូវកិច្ចប្រតិបត្តិប្រសើរបំផុតនិងសកម្មភាពដែលបានកំណត់គោលដៅសារជាថ្មី ឱ្យឆ្លើយតបដោយផ្ទាល់ចំពោះតំរូវការព័ត៌មានរបស់អ្នកទិញអន្តរជាតិនៃឧស្សាហកម្មនេះ។ កិច្ចប្រតិបត្តិល្អប្រសើរដែលកំពុងអនុវត្តបង្ហាញថា កម្មវិធីតាមដានថ្នាក់ជាតិដែលទទួលជោគជ័យបំផុតប្រាថ្នាឱ្យមានលក្ខណៈប្រាំពីរយ៉ាង ដែលដំណាក់កាលដំបូងនៃគំរោងវិស័យកាត់ដេររបស់កម្ពុជាបំពេញបាននូវលក្ខណៈពីរដំបូង និងបន្ទាប់មកឆ្លើយតបនឹងលក្ខណៈទីបី ប៉ុន្តែពុំមែនបំពេញលក្ខណៈបួនទៀតនោះទេ

## លក្ខណៈសំគាល់នៃ "គំរោងវិស័យកាត់ដេរ" នៅក្នុងប្រព័ន្ធកូតា

| លក្ខណៈសំគាល់ | ការវាយតំលៃ |
|---|---|
| រៀបចំដើម្បីៈ | |
| ១.ឱ្យមានលក្ខណៈទូលំទូលាយនៅក្នុងវិស័យ (មានគោលដៅសំរាប់ក្រុមហ៊ុន ១០០%) | ពិតដូច្នោះមែន |
| ២. ឱ្យមានតម្លាភាព | ពិតដូច្នោះមែន |
| ៣. ឱ្យមានរចនាសម្ព័ន្ធអភិបាលកិច្ចរួម | ទេ ប៉ុន្តែមានរចនាសម្ព័ន្ធប្រឹក្សារួម |
| ៤. បង្កឱ្យមានការចូលរួមពីអ្នកទិញអន្តរជាតិ | ទេ ប៉ុន្តែកំពុងចាប់ផ្តើម |
| ៥. កាត់បន្ថយអប្រសិទ្ធភាព | ទេៈ អ្នកទិញធ្វើឱ្យមានការតាមដានត្រួតជាន់គ្នា - ក្រសួងការងារបន្តធ្វើអធិការកិច្ចដូចធម្មតា |
| ៦. វាស់ស្ទង់ឥទ្ធិពលនៃផលិតភាព | ទេ ប៉ុន្តែមានកម្មវិធីវាស់ស្ទង់សាកល្បង |
| ៧. សំរេចបាននូវកត្តាលើកទឹកចិត្តលើមូលដ្ឋានទីផ្សារ | ទេៈ រង្វាន់កូតាពុំមែនផ្តល់ឱ្យចំពោះក្រុមហ៊ុនដែលអនុវត្តបានល្អបំភុតនោះទេ |

ផ្អែកលើការវាយតំលៃនេះ ដែលចែករំលែកដោយភាគីពាក់ព័ន្ធទាំងអស់ មានការរៀបចំយុទ្ធសាស្ត្រមួយដែលរួមមានលក្ខណៈសំគាល់ចំនួនប្រាំពីរ ផ្អែកលើឧត្តមភាពជំរុញលើកដំបូងរបស់កម្ពុជាដែលគេបានកំណត់អមដោយស្តង់ដារ និងសកម្មភាពតំរង់ទិសសារជាថ្មី ឆ្ពោះទៅរកការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់អ្នកទិញនិងភាគីពាក់ព័ន្ធនៅបរទេស។

យុទ្ធសាស្ត្រពុំមែនរក្សាទុកនូវគំរោងនៃវិស័យកាត់ដេររបស់ ILO នៅក្រោយពេលអន្តរកាលនោះទេ ប៉ុន្តែគឺធ្វើឱ្យមាននិរន្តរភាពនិងបញ្ចូលសកម្មភាពរបស់វាទៅក្នុងវិធីដែលឧស្សាហកម្មនេះដំណើរការ។ តាមបែបដូចគ្នានេះគណៈកម្មាធិការប្រឹក្សាគំរោងត្រីភាគីក្នុងពេលបច្ចុប្បន្ន (PAC) នឹងត្រូវជំនួសដោយអង្គភាព[1] គ្រប់គ្រងត្រីភាគី ដែលបានផ្តល់អាណត្តិការងារឱ្យពិនិត្យតាមដាន រាយការណ៍ សកម្មភាពដោះស្រាយនិងជំរុញលៃយ៉ាងណាឱ្យសកម្មភាពទាំងនេះអនុវត្តទៅតាមស្តង់ដារកេរ្តិ៍ខ្ពស់ ក្នុងការជួលនាយកប្រតិបត្តិនៃទីភ្នាក់ងារអនុវត្តន៍ និងដើម្បីពិនិត្យមើលដំណើរការនៃការជួលបុគ្គលិក។

កម្មវិធីនេះ ដែលរៀបចំដាក់ឈ្មោះសារជាថ្មីដោយ ILO ថារោងចក្រកាន់តែប្រសើរនៅកម្ពុជា (Better Factories Cambodia) មានបំណងបង្កើតឱ្យមានប្រព័ន្ធតាមដាននិងរាយការណ៍ស្តង់ដារការងារឯកភាពតែមួយដែល:

ក) ឆ្លើយតបនឹងតំរូវការព័ត៌មានស្តីពីស្តង់ដារការងាររបស់អ្នកលក់និងអ្នកទិញទាំងអស់

ខ) អូសទាញឱ្យមានការឆ្លើយតបរបស់ទីផ្សារ - វិជ្ជមាននិងអវិជ្ជមាន - និងស្វ័យរៀបចំគ្រប់គ្រងរបស់ឧស្សាហកម្ម

គ) កាត់បន្ថយយ៉ាងច្រើននូវការឃ្លាំមើលនិងអធិការកិច្ចដែលត្រួតជាន់គ្នានៅក្នុងឧស្សាហកម្មកាត់ដេរ

---

[1] អង្គភាពគ្រប់គ្រងត្រីភាគីគប្បីនៅតែជា GMAC ក្រសួងការងារ និងក្រសួងពាណិជ្ជកម្ម និងសហជីព។ វត្តមានជាផ្លូវការរបស់ ILO នៅឯ PAC គប្បីជំនួសដោយការចូលរួមរបស់ ILO ដោយពេញលេញនៅក្នុងអង្គភាពគ្រប់គ្រង និងអ្នកទិញនៅបរទេស ដែលគប្បីធ្វើការប្រឹក្សាជាមួយតាមរយៈវេទិកាពិគ្រោះយោបល់ប្រចាំឆ្នាំរបស់អ្នកទិញ។

ឃ) អនុញ្ញាតឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈផ្តោតការយកចិត្តទុកដាក់សារជាថ្មីនូវអធិការកិច្ចរបស់ខ្លួនលើឧស្សាហកម្មកាត់ដេរសំលៀកបំពាក់នាំចេញលើការអនុវត្តន៏ ការផ្សះផ្សា និងការងារបណ្តឹងតវ៉ា[2] ។

ខ្លឹមសារសង្ខេបនៃអនុសាសន៏ដែលចាំបាច់ត្រូវបំពេញគោលដៅនេះមានបង្ហាញដូចខាងក្រោម ។

| ផ្នែក-វិស័យ | បញ្ហា | អនុសាសន៏ | ស្ថានភាព | អាទិភាព |
|---|---|---|---|---|
| **I. ប្រព័ន្ធឃ្លាំមើលនិងរប្រព័ន្ធាយការណ៏** | | | | |
| ការចូលរួមរបស់ឧស្សាហកម្ម | ជៀសវាងបញ្ហាគ្មានច្បាប់ទម្លាប់ | ក្រសួងពាណិជ្ជកម្មចេញសេចក្តីប្រកាសមួយតំរូវឱ្យរោងចក្រនាំចេញទាំងអស់ចុះបញ្ជីគំរោងរបស់ខ្លួន | ទទួលការឯកភាពប៉ុន្តែនៅពុំទាន់អនុវត្ត | ខ្ពស់ |
| | | ក្រសួងពាណិជ្ជកម្មដាក់បញ្ចូលអ្នកម៉ៅការទៅក្នុងប្រព័ន្ធតាមដាន | នៅមិនទាន់អនុវត្ត | ខ្ពស់-មធ្យម |
| | | ក្រសួងពាណិជ្ជកម្មពន្យល់ច្បាប់ចំពោះតំបន់កែច្នៃឧសសាហកម្ម ហើយច្បាប់នេះនឹងអនុវត្តទាំងស្រុង | នៅមិនទាន់អនុវត្ត | មធ្យម-ទាប |
| **II. តំរូវការក្នុងការរាយការណ៏និងតំរូវការព័ត៌មាន** | | | | |
| លទ្ធផលនៃប្រព័ន្ធតាមដាន | ឆ្លើយតបចំពោះតំរូវការព័ត៌មានរបស់ភាគីពាក់ព័ន្ធ | រាជរដ្ឋាភិបាលកម្ពុជាវាយតំលៃរាល់តំរូវការព័ត៌មានស្តីពីអធិការកិច្ចរបស់ក្រសួង | ណ្ឌ្យត យតេ ាងរដេ | ដើម |
| | | ILO វាយតំលៃកង្វះខាតក្នុងលក្ខណៈជាប្រព័ន្ធរវាងតំរូវការរបស់អ្នកទិញនិងលទ្ធផលរបស់ប្រព័ន្ធបច្ចុប្បន្ន | នៅមិនទាន់ឯកភាព | មធ្យម |
| | | ILO ពិភាក្សាអំពីជំរើសសំរាប់ការចូលរួមរបស់អ្នកទិញ | បានឯកភាពនិងកំពុងដំណើរការ | ខ្ពស់ |
| កត្តាលើកទឹកចិត្ត | កាត់បន្ថយបន្ទុកអធិការកិច្ច | ក្រសួងមហាផ្ទៃទទួលលទ្ធផលនៃប្រព័ន្ធនេះ មិនត្រួតជាន់គ្នា ហើយផ្តោតលើបណ្តឹងតវ៉ា ការអនុវត្តន៏ និងការផ្សះផ្សា | បានឯកភាពក្នុងការពិចារណា | ិះងហ |

---

[2] ទិដ្ឋភាពនឹងតំរូវឱ្យមានការពិភាក្សាបន្ថែមជាមួយក្រសួងការងារ និងជាមួយសហការីឯទៀតនៅក្នុង ILO ។ ចាំបាច់ត្រូវមានការការពារគ្រប់គ្រាន់ ប៉ុន្តែគេសង្ឃឹមថាអធិការកិច្ចរបស់រដ្ឋាភិបាលនៅពេលណាមួយក៏អាចពឹងផ្អែកលើកម្មវិធីឃ្លាំមើលនេះចំពោះផ្នែកសំខាន់ៗនៃច្បាប់ការងារដែរ ។

| | | | | |
|---|---|---|---|---|
| | | ក្រសួងពាណិជ្ជកម្មធ្វើទំនាក់ទំនងជាមួយក្រសួងហិរញ្ញវត្ថុ ក្នុងការដោះស្រាយបញ្ហាស្តីពីអាករលើតំលៃបន្ថែម ដែលជាឧបសគ្គក្នុងការរៀបចំកិច្ចព្រមព្រៀងម៉ៅការបន្ត | ណរ្យិត យតេ ាងរដេ | ខ្ពស់ |
| តម្លាភាព | ធានាឱ្យមានជំនឿទុកចិត្ត ដែលមាននិរន្តរភាពអំពីប្រព័ន្ធនេះ | PAC ឯកភាពក្នុងការផ្លាស់ប្តូរគណៈកម្មការប្រឹក្សាទៅជាអង្គភាពគ្រប់គ្រងត្រីភាគីចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០០ | បានឯកភាពនៅក្នុងវិស័យទាំងបី | ខ្ពស់ |
| | | PAC ធានាឱ្យមានតម្លាភាពជាបន្តនៃប្រព័ន្ធព័ត៌មានថ្មី | បានឯកភាព | ខ្ពស់ |
| | | PAC ធានាឱ្យមានការពិគ្រោះពេញលេញលើដំណើរការសំរាប់បង្កើតទីភ្នាក់ងារអនុវត្តន៍ | បានឯកភាព | មធ្យម |
| ការឃ្លាំមើលជាបន្ត | | គណៈកម្មការរបស់ក្រសួងពាណិជ្ជកម្មធ្វើអង្កេតសារចុះសារឡើងអំពីលក្ខណ្ឌរកប្រភពនិងបំណងទិញទំនិញរបស់អ្នកទិញ | នៅមិនទាន់ឯកភាព | មធ្យម |
| | | ILO បង្កើតសូចនាករសាកល្បងសំរាប់វាស់ស្ទង់ការកែលំអលក្ខណ្ឌការងារ គុណភាព និងផលិតភាព | បានឯកភាព | ខ្ពស់ |
| | | ILO និងGMAC តាមដានក៏រិតប្រាក់ចំណេញរបស់រោងចក្រ ដែលបានមកពីការបណ្តុះបណ្តាលការងារដោះស្រាយវិបត្តិ | បានឯកភាពនិងកំពុងដំណើរការ | ខ្ពស់ |
| ការជំរុញ | រកទីផ្សារឱ្យឧត្តមភាពច្បាស់លាស់របស់ប្រទេស | យុទ្ធសាស្រ្តឯកភាពជំរុញរបស់ PAC រួមទាំងក្រុមប្រឹក្សាវិនិយោគថ្មីរបស់កម្ពុជាផងដែរ | មិនទាន់ឯកភាព | |
| **II. ហិរញ្ញប្បទាន** | | | | |
| ប្រព័ន្ធឃ្លាំមើលនិងរាយការណ៍ | ធានាឱ្យមាននិរន្តរភាព | PAC ឯកភាពក្នុងការចែករំលែកយុទ្ធសាស្រ្តផ្តល់ ហិរញ្ញប្បទាន | បានឯកភាព | ខ្ពស់ |
| | | ILO ផ្តួចផ្តើមការពិភាក្សាអំពីការបង្កើតទីផ្សារសំរាប់សេវាកែ តំរូវសេវាកសាងសមត្ថភាព | បានឯកភាពនិងំពូងដំណើរការ | ទាប |
| **III. ទីផ្សារការងារ** | | ក្រសួងមហាផ្ទៃចាំបាច់ត្រូវពិនិត្យមើលច្បាប់ការងារសារឡើងវិញដោយមានជំនួយបច្ចេកទេសពី ILO | បានឯកភាព | មធ្យម |
| | | ក្រសួងមហាផ្ទៃនិង GMAC ពិចារណាអំពីតំរូវការសំរាប់កែតំរូវសេវាក្នុងពេលដែលរំពឹងថាមានវិបត្តិ | មិនទាន់ឯកភាព | មធ្យម |

ជាជំហានចុងក្រោយនៃគំរោងប្រឹក្សានេះ ក្រសួងពាណិជ្ជកម្មបានស្នើសុំឱ្យ FIAS ពិចារណាអំពីសក្តានុពលនៃផលប៉ះពាល់នៃស្តង់ដារការងាររបស់វិស័យកាត់ដេរសំលៀកបំពាក់ ផ្តោតលើវិស័យឧស្សាហកម្មដទៃ។

ដោយសារសារៈសំខាន់នៃវិស័យទាំងនោះគិតជា GDP ដោយសារសក្តានុពលនៃឱកាសការងារនិងកំណើនវិស័យដែលបានលើកយកញមកធ្វើការពិនិត្យមើលរួមមានវិស័យទេសចរណ៍ កសិអាជីវកម្ម ព្រៃឈើ ឥន្ធនៈ និងឧស្ម័ន។ មានបញ្ហាពីដែលត្រូវបានលើកយកមកពិចារណាៈ ទីមួយ សក្តានុពលនៃឧត្តមភាពប្រៀបធៀបនៃស្តង់ដារការងារ និងស្តង់ដារបរិស្ថាននៅក្នុងវិស័យទាំងនេះ ទីពីរសក្តានុពលនៃមធ្យោបាយសំរាប់ឱ្យរដ្ឋាភិបាលលើកទឹកចិត្តនូវកិច្ចប្រតិបត្តិល្អ។

ការវិភាគនិងឧទាហរណ៍នៃកិច្ចប្រតិបត្តិល្អនៅក្នុងផ្នែកទី ៥ បង្ហាញថាប្រព័ន្ធនិងមធ្យោបាយមានលក្ខណៈស្រដៀងគ្នាជាខ្លាំងធៀបជាមួយនឹងប្រព័ន្ធនិងមធ្យោបាយដែលបានបង្កើតនៅក្នុងឧស្សាហកម្មកាត់ដេរអាចយកទៅអនុវត្តនៅក្នុងឧស្សាហកម្មដទៃទៀតបាន។ នៅក្នុងវិស័យទាំងអស់ចំនួនបួន ការបង្កើតស្តង់ដារជាតិ ការដាក់ឱ្យមាននូវរចនាសម្ព័ន្ធនិងស្ថាប័នតាមដាននិងផ្តល់វិញ្ញាបនប័ត្រដែលអាចជឿទុកចិត្តបាន សំរួលលទ្ធភាពឱ្យបានទទួលហិរញ្ញប្បទាន ការទទួលស្គាល់កម្មវិធីផ្តល់វិញ្ញាបនប័ត្រអន្តរជាតិជាកិច្ចការដូចគ្នានឹងអធិការកិច្ចរបស់វិស័យសាធារណៈ ការតាមដាន ការធ្វើការនៅក្នុងប្រព័ន្ធអភិបាលកិច្ចរួម ។ល។ គឺស្ថិតនៅក្នុងឧបករណ៍រួមដែលអាចទ្រទ្រង់ចក្ខុវិស័យរបស់រដ្ឋាភិបាលនៃប្រទេសមួយដែលប្តូរប្តេជ្ញចំពោះស្តង់ដារការងារ និងស្តង់ដារបរិស្ថាន ដោយផ្អែកលើរចនាសម្ព័ន្ធនិងបទពិសោធន៍មានស្រាប់ដែលបានទទួលពីវិស័យកាត់ដេរ។